# ការយល់ឃើញរបស់ថ្នាក់ដឹកនាំសង្គមស៊ីវិលនិងសហជីព អំពីសេរីភាពមូលដ្ឋាននៅកម្ពុជា ការវិវឌ្ឍន៍ក្នុងរយៈពេល៩ឆ្នាំ ២០១៦-២០២៤

គម្រោងឃ្លាំមើលសេរីភាពមូលដ្ឋាន គឺជាគម្រោងធ្វើការឃ្លាំមើលលំហសង្គមស៊ីវិលនៅកម្ពុជា ជាពិសេសឃ្លាំមើលទៅលើលទ្ធភាពរបស់បុគ្គលដែលអាចអនុវត្តសេរីភាពខាងសមាគម សេរីភាពខាងការបញ្ចេញមតិ និងសេរីភាពខាងការជួបប្រជុំ (សេរីភាពមូលដ្ឋាន)។ គម្រោងធ្វើការស្ទង់មតិប្រចាំឆ្នាំ ជាមួយថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងថ្នាក់ដឹកនាំសហជីព ដើម្បីវាស់ស្ទង់ថាតើថ្នាក់ដឹកនាំនីមួយៗមានសេរីភាពក្នុងការអនុវត្តសេរីភាពមូលដ្ឋានរបស់ខ្លួនកម្រិតណា។




នៅឆ្នាំ២០២៤ គម្រោងបានស្ទង់មតិថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពចំនួន ១៦៣ តំណាងឱ្យអង្គការសង្គមស៊ីវិល និងសហជីពដែលអនុវត្តសកម្មភាពនៅក្នុងប្រទេសកម្ពុជា។




ទិន្នន័យប្រមូលបានក្នុងឆ្នាំ២០២៤ បង្ហាញថាមានការកើនឡើងចំនួន១៤% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលនិងសហជីពដែលរាយការណ៍ ថាខ្លួនបានប្រឈមនឹងការរឹតត្បិតក្នុងការបង្កើតជាបណ្តាញ សម្ព័ន្ធ សហព័ន្ធ និងសហជីព ពី ៣១% នៅឆ្នាំ២០២៣ រហូតដល់ ៤៥% នៅឆ្នាំ២០២៤។ ការបង្កើតជាបណ្តាញ សម្ព័ន្ធ ឬសហជីព មានសារៈសំខាន់ណាស់ ដោយអាចបង្កើនប្រសិទ្ធភាព ព្រមទាំងឥទ្ធិពលរបស់សង្គមស៊ីវិល និងសហជីពក្នុងការលើកកម្ពស់ការផ្លាស់ប្តូរសង្គម និងអភិបាលកិច្ចប្រជាធិបតេយ្យ ហើយសកម្មភាពទាំងនេះស្ថិតក្រោមសេរីភាពខាងសមាគមដែលធានាដោយច្បាប់ជាតិនិងអន្តរជាតិ។

ចំនួនថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានរាយការណ៍ថារដ្ឋាភិបាលបានតាមដានសកម្មភាពរបស់ខ្លួន បានកើនឡើងចំនួន ៩% ពី ៣៧% នៅក្នុងឆ្នាំ២០២៣ រហូតដល់ ៤៦% នៅក្នុងឆ្នាំ២០២៤។ ទាំងក្រោមច្បាប់ជាតិ និងច្បាប់អន្តរជាតិ អង្គការសង្គមស៊ីវិលទាំងនេះមានសិទ្ធិអនុវត្តសកម្មភាពស្របច្បាប់របស់ពួកគេដោយគ្មានការជ្រៀតជ្រែក។






នៅឆ្នាំ២០២៣ ៥៨% នៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពរកឃើញថារដ្ឋាភិបាលបានតាមដានសកម្មភាពរបស់ពួកគេហួសហេតុ។ ចំណុចនេះបានកើនឡើងរហូតដល់ទៅ ៦១% នៅក្នុងឆ្នាំ២០២៤ ដែលនាំឱ្យមានការព្រួយបារម្ភកាន់តែខ្លាំង។ នេះជាចំណុចគួរឱ្យកត់សម្គាល់ថា នៅក្នុងរយៈពេលនៃការអនុវត្តគម្រោងនេះ ភាគច្រើននៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព បានបង្ហាញការព្រួយបារម្ភជាបន្តបន្ទាប់អំពីការតាមដានហួសហេតុរបស់រដ្ឋាភិបាល។

នៅឆ្នាំ២០២៤ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលរាយការណ៍ថាមានសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី បានធ្លាក់ចុះបន្តិចត្រឹម ២% ដោយថយចុះពី ៦០% នៅក្នុងឆ្នាំ២០២៣ មកត្រឹម ៥៨% នៅក្នុងឆ្នាំ២០២៤។ ការថយចុះនេះអាចបណ្តាលមកពីបញ្ហាប្រឈមដែលពួកគេបានជួបប្រទះក្នុងអំឡុងឆ្នាំ២០២៤ ជាពិសេសក្នុងការរៀបចំការប្រារព្ធទិវាអន្តរជាតិ នៅក្រោមលក្ខខណ្ឌដ៏តឹងរ៉ឹង រួមមានការព្រួយបារម្ភអំពីសុវត្ថិភាព សន្តិសុខ និងភាពស្មុគស្មាញផ្នែកច្បាប់ក្នុងករណីមានបញ្ហាណាមួយកើតឡើងក្នុងអំឡុងពេលរៀបចំកម្មវិធីនោះ។ ស្រដៀងគ្នានេះដែរ ចំនួនថ្នាក់ដឹកនាំដែលយល់ថាមានសេរីភាពក្នុងការបញ្ចេញមតិបានថយចុះចំនួន ៤% ពី ៥៨% ក្នុងឆ្នាំ២០២៣ មកត្រឹម ៥៤% ក្នុងឆ្នាំ២០២៤។ ទំនោរនៃការធ្លាក់ចុះជាបន្តបន្ទាប់នេះបង្កជាការព្រួយបារម្ភ ដោយសារតែសញ្ញានេះបានបង្ហាញថា ការធ្វើឱ្យថមថយសេរីភាពមូលដ្ឋានរបស់សង្គមស៊ីវិលនៅកម្ពុជានៅតែកើតមាន។







នៅឆ្នាំ២០២៣ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថាមានអារម្មណ៍មិនមានសុវត្ថិភាពក្នុងការបញ្ចេញមតិរបស់ពួកគេនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គមមានចំនួន ១៦% ដែលថយចុះគួរឱ្យកត់សម្គាល់ត្រឹម១៧%នៅឆ្នាំមុនៗ។ ទំនោរធ្លាក់ចុះនេះ បានបន្តរហូតដល់ឆ្នាំ ២០២៤ ដែលនៅសល់ត្រឹម ១៦% ដែលចំនួននេះជាចំនួនភាគរយទាបបំផុតចាប់តាំងពីមានការប្រមូលទិន្នន័យនៅឆ្នាំ២០១៧ មក។

នៅឆ្នាំ២០២៤ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលបានរាយការណ៍ថា "ជានិច្ចកាល" "ជាប្រចាំ" ឬ "នៅពេលខ្លះ" បានរឹតត្បិតសេរីភាពខ្លួនឯង ដោយសារតែមានការភ័យខ្លាចការតបតបានថយចុះ ៥% ពី ៨០% នៅឆ្នាំ២០២៣ មកត្រឹម ៧៥% នៅឆ្នាំ២០២៤។ ទោះជាយ៉ាងណាក៏ដោយ នេះនៅតែជាកត្តាមួយដែលគួរឱ្យព្រួយបារម្ភ ពីព្រោះថ្នាក់ដឹកនាំភាគច្រើន នៅតែយល់ឃើញថាត្រូវដាក់កំហិតខ្លួនឯងមិនតិចជាង ៨០% នោះទេ ចាប់តាំងពីការចាប់ផ្តើមគម្រោង។ សេរីភាពខាងការបញ្ចេញមតិគឺមានសារៈណាស់សម្រាប់សង្គមទាំងមូលដែលជួយឱ្យមានសុខមាលភាពសង្គមស៊ីវិល និងការពារសិទ្ធិប្រជាធិបតេយ្យ។



ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលរាយការណ៍ថារដ្ឋាភិបាលបានទទួលស្គាល់ជាដៃគូអភិវឌ្ឍន៍ស្របច្បាប់ និងមានសមត្ថភាព




នៅឆ្នាំ២០២៤ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព ដែលយល់ថា ត្រូវបានរដ្ឋាភិបាលទទួលស្គាល់ជាដៃគូស្របច្បាប់មានការកើនឡើងគួរឱ្យកត់សម្គាល់ពោលគឺ១៣% ដែលកើនឡើងពី ៥៤% នៅឆ្នាំ២០២៣ ដល់ ៦៧% នៅឆ្នាំ២០២៤។ ផ្ទុយទៅវិញ ភាគរយនៃអង្គការសង្គមស៊ីវិល និងសហជីព ដែលយល់ថាត្រូវបានទទួលស្គាល់ថាជាដៃគូអភិវឌ្ឍន៍ប្រកបដោយសមត្ថភាពមានការថយចុះ១% ពី៥០% នៅឆ្នាំ២០២៣ មកត្រឹម ៤៩% នៅឆ្នាំ២០២៤។

ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលរាយការណ៍ថាបានចូលរួមក្នុងដំណើរការធ្វើសម្រេចចិត្ត និងតាក់តែងច្បាប់ជាមួយរដ្ឋាភិបាល




រវាងឆ្នាំ២០២៣ និងឆ្នាំ២០២៤ មានការប្រែប្រួលតិចតួចនៃការចូលរួមរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព។ នៅឆ្នាំ២០២៣ មានត្រឹមតែ២% ប៉ុណ្ណោះនៃថ្នាក់ដឹកនាំឆ្លើយថាបានចូលរួមធ្វើសេចក្តីសម្រេចចិត្ត "ញឹកញាប់ណាស់" និង ២% ឆ្លើយថា "ញឹកញាប់"។ នៅឆ្នាំ២០២៤ ភាគរយទាំងនេះប្តូរមកត្រឹម ១% និង ៤% រៀងគ្នា។ ទោះយ៉ាងណាក៏ដោយ នេះជាចំណុចសំខាន់ដែលគួរកត់សម្គាល់ថា របត់នៃការចូលរួមរបស់ថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីព គឺមានកម្រិតទាបនៅឡើយចាប់តាំងពីការចាប់ផ្តើមអនុវត្តគម្រោង។ ភាគរយនៃថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិល និងសហជីពដែលបានរាយការណ៍ពីការចូលរួម "នៅពេលខ្លះ" មិនដែលលើសពី ៣១% នោះទេនៅគ្រប់ឆ្នាំទាំងអស់នៃគម្រោង។ ចំណេះដឹង និងបទពិសោធន៍ដ៏មានតម្លៃរបស់អង្គការសង្គមស៊ីវិល និងសហជីពអាចរួមចំណែកយ៉ាងសំខាន់ដល់ការអនុវត្តគោលនយោបាយឱ្យកាន់តែមានប្រសិទ្ធភាព និងនិរន្តរភាព។ ធាតុចូលរបស់ពួកគេគឺចាំបាច់ណាស់សម្រាប់ការធានាដល់ការបង្កើត និងអនុវត្តគោលនយោបាយ និងច្បាប់ឆ្លើយតបនឹងតម្រូវការ ដែលផ្តល់ផលប្រយោជន៍ដល់កម្មករ និងសម្រាប់សង្គមទាំងមូល។




មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

សមាគមអាដហុក
ADHOC

ខែកុម្ភៈ ឆ្នាំ២០២៥



BY NC SA